# យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា
# ឆ្នាំ ២០១៨ ~ ២០២៥

## ប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃសុក្រ ១១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨

**ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នាថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៨**

# មាតិកា

(ស្របតាមជំពូកនៃឯកសារ)

១. សាវតានៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) & ការកែទម្រង់ប្រព័ន្ធថវិកា (BSR) នៅកម្ពុជា

២. ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកា

៣. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥

៤. ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រឆ្នាំ ២០២៥

៥. សេចក្តីសន្និដ្ឋាន

# ១.សាវតានៃ PFMRP & BSR នៅកម្ពុជា

- PFMRP ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅឆ្នាំ ២០០៤ ដើម្បី **«កសាងមូលដ្ឋានគ្រឹះចាំបាច់ ឆ្ពោះទៅរៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា»** តាមអភិក្រម ៤ ជំហាន ដោយអនុវត្តជា ៤ ដំណាក់កាល គឺ ÷

  ជំហានទី១ - ភាពជឿទុកចិត្តបាននៃថវិកា,

  ជំហានទី២ - គណនេយ្យភាពហិរញ្ញវត្ថុ,

  ជំហានទី៣ - ការផ្សារភ្ជាប់គ្នារវាងថវិកា និងគោលនយោបាយ,

  ជំហានទី៤ - គណនេយ្យភាពសមិទ្ធកម្ម ។

- ដំណាក់កាលនីមួយៗផ្ដោតលើជំហានមួយជាក់លាក់ ហើយទន្ទឹមនឹងនេះ បន្តពង្រឹងជំហានមុនផង និង ត្រៀមរៀបចំកសាងមូលដ្ឋានគ្រឹះសម្រាប់ជំហានបន្ទាប់ផង។

# ១.សាវតានៃ PFMRP & BSR នៅកម្ពុជា (ត)

- ជំហានទី១ និងជំហានទី២ ទទួលបានជោគជ័យសំខាន់ៗជាច្រើន ប៉ុន្តែក៏នៅមានសេសសល់ការងារដែលត្រូវបន្តកែលម្អ និងពង្រឹង។ ជំហានទី៣ បានចាប់ផ្តើមនៅឆ្នាំ ២០១៦ ដោយគ្រោងនឹងសម្រេចឱ្យបាននៅឆ្នាំ ២០២០ ។
- ដើម្បីត្រៀមអនុវត្តជំហានទី៣, **ឯកសារទស្សនទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០** ត្រូវបានដាក់ចេញដោយបានកំណត់ទិសដៅនៃការកែទម្រង់ពី «*ប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ*» ឈានឆ្ពោះទៅរក «*ប្រព័ន្ធថវិកាផ្អែកលើលទ្ធផល/សមិទ្ធកម្ម និងវិមជ្ឈការ*»។

# ១.សាវតារនៃ PFMRP & BSR នៅកម្ពុជា (ត)

➤BSR មកដល់ពេលនេះ សម្រេចបាននូវវឌ្ឍនភាពសំខាន់ៗ ដូចខាងក្រោម÷

- បានអនុវត្តសាកល្បងថវិកាកម្មវិធីពេញលេញជាបណ្តើរៗ ចាប់ពីឆ្នាំ ២០១៥ និងឈានទៅអនុវត្តនៅគ្រប់ក្រសួងស្ថាប័ន នាឆ្នាំ ២០១៨
- ពន្លឿនការដាក់ឱ្យអនុវត្តអង្គភាពថវិកា ដែលអាចរុញធនធានទៅដល់ដៃអង្គភាពប្រតិបត្តិផ្ទាល់
- FMIS ត្រូវបានបង្កើតឡើង និងដាក់អនុវត្តដល់គ្រប់អគ្គ-នាយកដ្ឋានរបស់ក.ស.ហ.វ និងរតនាគាររាជធានី-ខេត្ត

# ១.សាវតានៃ PFMRP & BSR នៅកម្ពុជា (ត)

- ឯកសារទស្សនទាន (២០១៣-២០២០) មានភាពចាំបាច់ដើម្បីពិនិត្យឡើងវិញ ព្រោះចាប់តាំងពីពេលចាប់ផ្តើមមកដល់ពេលនេះ បានពាក់កណ្តាលផ្លូវហើយ ។ ទន្ទឹមនឹងនេះ បរិការណ៍មានការប្រែប្រួលជាច្រើន ក្នុងអភិក្រមឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្ម ទាំងក្នុងប្រទេស និងទាំងអន្តរជាតិ។

- កិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦ ក្រោមការដឹកនាំរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី** បានសម្រេចឱ្យរៀបចំ **យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា** សម្រាប់ជាមូលដ្ឋានកែទម្រង់រយៈពេលវែង និងគ្រប់ជ្រុងជ្រោយ ដោយកំណត់ក្របខ័ណ្ឌពេលវេលាឱ្យស៊ីគ្នាទៅនឹង PFMRP។

# ២. ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកា

## អភិក្រមនៃការរៀបចំ BSRS

- មានភាពប្រាកដនិយម - ស្របតាមឧត្តមានុវត្តអន្តរជាតិ
- មានភាពជាក់ស្តែងនិយម - ស្របទៅនឹងបរិការណ៍កម្ពុជា
- បោះជំហានព្យាសកម្ម - ប្រយ័ត្នប្រយែង តែសកម្ម និង មានការប្តេជ្ញាចិត្តខ្ពស់
- សម្របតាមគោលដៅជំហានទី៤ នៃ PFM - គណនេយ្យភាពសមិទ្ធកម្ម ឆ្នាំ២០២៥

# មូលដ្ឋាននៃការរៀបចំ BSRS

- ឯកសារពាក់ព័ន្ធនឹង PFMRP នៅកម្ពុជា ជាពិសេសឯកសារទស្សនទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃ BSR (២០១៣ - ២០២០)
- បទពិសោធន៍របស់កម្ពុជា ក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ
- ការវាយតម្លៃការអនុវត្តថវិកាកម្មវិធីពេញលេញដោយ WB/PFM
- ឯកសារស្តីពី PFM និងនិម្មាបនកម្មថ្មី,២០១៣, របស់ IMF
- បទពិសោធន៍អន្តរជាតិៈ ម៉ាឡេស៊ី, ថៃឡង់ដ៍, ស៊ុយអែត , បារាំង ...
- ចំណេះដឹង និងបទពិសោធន៍ផ្សេងៗគ្នា នៃជំនាញការបរទេស
- ការពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធគន្លឹះៗ
- ការផ្តល់ធាតុចូលបន្ថែមពី DPs ពាក់ព័ន្ធសំខាន់ៗ ។

# ២. ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកា (ត)

- **ថវិកាសមិទ្ធកម្មត្រូវបានធ្វើចំណាត់ថ្នាក់ជា ៣ម៉ូដែលគឺ÷** ប្រព័ន្ធថវិកាបង្ហាញសមិទ្ធកម្ម, ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម, ប្រព័ន្ធថវិកាសមិទ្ធកម្មផ្ទាល់ ឬប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម

- **សម្រេចកែសម្រួល<u>ទិសដៅនៃថវិកាសមិទ្ធកម្ម</u>÷**

  - **ពីប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម (Performance based budgeting)** ឬថវិកាសមិទ្ធកម្មផ្ទាល់ (Direct performance budgeting) : ដែលទំហំថវិកាត្រូវបានវិភាជ ដោយផ្អែកខ្លាំងលើព័ត៌មានសមិទ្ធកម្ម

  - **ទៅជាប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម (Performance-informed budgeting)**: ដែលតាមម៉ូដែលនេះ ព័ត៌មានសមិទ្ធកម្មត្រូវបានប្រើប្រាស់ក្នុងការបែងចែកធនធាន និងការវិភាជថវិកា, ប៉ុន្តែទន្ទឹមនឹងនេះ ក៏ផ្អែកលើភាពចាំបាច់ និងជាក់ស្តែងផងដែរ។

# ៣. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ ២០១៧-២០២៥

១. ការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ

*(ផែនការរយៈពេលមធ្យម)*

២. ការរៀបចំ និងអនុម័តថវិកាប្រចាំឆ្នាំ

៣. ការអនុវត្ត និងត្រួតពិនិត្យថវិកា

៤. ការវាយតម្លៃ និង ការតាមដានថវិកា

៥. ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការកែទម្រង់

៦. ការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ

# ៣.១. ការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ

- ***ម៉ាក្រូសេដ្ឋកិច្ច÷*** ពង្រឹងគុណភាពការព្យាករម៉ាក្រូសេដ្ឋកិច្ច
- ***ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF)÷*** កំណត់គោលដៅសារពើពន្ធសរុប, ពិដានឱនភាពថវិកា, ពិដានតាមប្រភេទចំណាយ និងតាមវិស័យ, និងហានិភ័យថវិកា (**សម្រេចដោយកិច្ចប្រជុំគណៈរដ្ឋមន្ត្រី**) ។
- ***ក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) ÷*** លម្អិតបន្ថែមទៀត ដល់កម្រិតក្រសួង-ស្ថាប័ន, រាជធានី-ខេត្ត, ក្រុង-ស្រុក, ឃុំ-សង្កាត់ ទាំងចំណាយចរន្តនិងចំណាយវិនិយោគ ។ ក្របខណ្ឌនេះរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកតាមអាទិភាព និងតាមសមិទ្ធកម្ម (**សម្រេចដោយនាយករដ្ឋមន្ត្រី**) ។
- ***ផែនការយុទ្ធសាស្ត្រថវិកា (BSP) របស់បណ្តាក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត÷*** រៀបចំដោយក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ដើម្បីពិនិត្យតម្រូវការថវិការយៈពេលមធ្យម។ BSP ត្រូវបន្តពង្រឹងដោយមានសមាហរណកម្មថវិកាចរន្ត និងវិនិយោគគ្រប់ប្រភពធនធានសាធារណៈរបស់រដ្ឋ ។

# ៣.២. ការរៀបចំ និង ការអនុម័តថវិកា

- ការរៀបចំថវិកា និងការពិភាក្សា និងអនុម័តថវិកាដោយស្ថាប័ននីតិ-ប្បញ្ញត្តិ នឹងផ្អែកលើកម្មវិធី (២០២២) និងចំណាត់ថ្នាក់សេដ្ឋកិច្ចបំពេញ (បៀវត្ស, មិនមែនបៀវត្ស, មូលធន) និងមានភ្ជាប់ព័ត៌មានសមិទ្ធកម្ម (២០២៥)
- ក្រសួង ស្ថាប័ននឹងការពារកម្មវិធីរបស់ខ្លួននៅក្នុងការពិភាក្សាដេញដោលដោយគណៈកម្មការជំនាញនៃស្ថាប័ននីតិប្បញ្ញត្តិ (រួមគ្នានៅរដ្ឋសភា)
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងទទួលខុសត្រូវក្នុងការការពារកញ្ចប់ថវិកាតាមក្រសួង-ស្ថាប័ន និងតាមគោលនយោបាយ និងកម្មវិធី ដែលជាឧបសម្ព័ន្ធនៃថវិកា នៅគណៈកម្មការទី២ និងនៅក្នុងកិច្ចប្រជុំពេញអង្គនៃស្ថាប័ននីតិប្បញ្ញត្តិ តែការអនុម័តនឹងត្រូវធ្វើតាមជំពូកនីមួយៗនៃច្បាប់

# ៣.៣ ការអនុវត្តថវិកា និងការត្រួតពិនិត្យចំណាយ

- ច្បាប់ថវិកានឹងជាមូលដ្ឋាននៃការអនុញ្ញាតឱ្យបញ្ជាចំណាយសម្រាប់ក្រសួង-ស្ថាប័ន តាមរយៈកម្មវិធីចំណាយប្រចាំត្រីមាស/ ឆមាស ស្របតាមគោល-ការណ៍កំណត់, លើកលែងតែមុខចំណាយមួយចំនួនដែលមានទំហំធំ, មិនមានគោលការណ៍/ គោលរបបច្បាស់លាស់ និង/ ឬមានវេទយិតភាពខ្ពស់
- បង្កើតតួនាទី «**អភិបាលថវិកា**» ដែលប្រមូលផ្តុំមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្ម និងមុខងារត្រួតពិនិត្យលើការអនុវត្តចំណូល នៅអមក្រសួង-ស្ថាប័នផ្ទាល់; ដោយឡែក ក្របខ័ណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យការបើកផ្តល់នឹងត្រូវធ្វើសមញ្ញកម្ម និងប្រើប្រព័ន្ធ FMIS
- កិច្ចលទ្ធកម្មៈ ពង្រឹងតួនាទីនិយ័តករ និងឯករាជ្យភាពនៃយន្តការដោះស្រាយជម្លោះ ព្រមទាំងធ្វើប្រតិភូកម្មសិទ្ធិអំណាច និងការទទួលខុសត្រូវនៃការអនុវត្តកិច្ចលទ្ធកម្មទៅក្រសួង-ស្ថាប័នពាក់ព័ន្ធ

# ៣.៤ ការតាមដានថវិកា និងការវាយតម្លៃ

- **របាយការណ៍៖**
  - របាយការណ៍ហិរញ្ញវត្ថុ៖ តាមទម្រង់ «សាច់ប្រាក់កែសម្រួល» នៃស្តង់ដារគណនេយ្យសាធារណៈអន្តរជាតិ (Modified Cash-IPSAS)
  - របាយការណ៍សមិទ្ធកម្ម៖ តាមកម្មវិធី និងអនុកម្មវិធី ដោយមានប្រព័ន្ធតាមដាន និងវាយតម្លៃជាសារវ័ន្ត ដើម្បីពិនិត្យមើលការសម្រេចបាននូវគោលបំណង និងលទ្ធផលដែលបានគ្រោងទុក

- **ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី ៖**
  - ការតាមដានជាប្រចាំ៖ ក្រសួង ស្ថាប័ន
  - ការតាមដានពាក់កណ្តាលឆ្នាំ និងការវាយតម្លៃប្រចាំឆ្នាំ៖ កសហវ/ក្រសួង-ស្ថាប័ន
  - ការវាយតម្លៃស៊ីជម្រៅ (ក្នុងពេលអនុវត្ត និងក្រោយបញ្ចប់ការអនុវត្ត) : ក.ស.ហ.វ/ ក្រសួង-ស្ថាប័ន (តាមការចាំបាច់/មានកម្រិត)
  - ការសិក្សាពិនិត្យចំណាយឡើងវិញ : ក.ស.ហ.វ (តាមការជ្រើសរើស)
  - ការតាមដាន និងវាយតម្លៃឯករាជ្យ : អាជ្ញាធរសវនកម្មជាតិ

# ៣.៥ ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនឹងត្រូវធ្វើវិសោធនកម្ម ដើម្បីផ្តល់ភាពស្របច្បាប់ពេញលេញក្នុងដំណើរការផ្លាស់ប្តូរឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្ម
- «ឌីជីថលនីយកម្ម» តាមប្រព័ន្ធ FMIS សម្រាប់វដ្តថវិកាទាំងមូល: ការរៀបចំ ការអនុវត្ត និងការធ្វើរបាយការណ៍
- ការលើកកម្ពស់សមត្ថភាពជំនាញ PFM រួមមាន: ការវិភាគថវិកា, ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ, FMIS, កិច្ចលទ្ធកម្ម, ការគ្រប់គ្រងគម្រោង, និង ការតាមដាននិងវាយតម្លៃ ។ល។

# ៣.៦. ការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ

➢ **គោលបំណងរួម:**

❑ ផ្តោតលើការពង្រឹងទំនាក់ទំនងគ្នា ដោយបំពេញគ្នា និងប្រទាក់គ្នា រវាង BSP រាជធានី ខេត្ត ជាមួយនឹង BSP ថ្នាក់ជាតិ ដើម្បីសម្រេចគោលនយោបាយ និងអាទិភាពរួមរបស់ជាតិ <u>ជាពិសេស</u> :

- កែលម្អដំណើរការប្រឹក្សាយោបល់ និងការសម្របសម្រួលរវាងក្រសួងស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការវិសហមជ្ឈការ
- ជំរុញការបែងចែកមុខងារឱ្យកាន់តែច្បាស់លាស់ រវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

# ៣.៦. ការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ (ត)

- ផ្តោតលើសមាហរណកម្មនៃការរៀបចំ BSP រាជធានី ខេត្ត ដែលគ្រប-ដណ្តប់ថវិការាជធានី-ខេត្ត, ក្រុង-ស្រុក, និងឃុំ-សង្កាត់ ដោយ :
  - បន្សុីគ្នាអំពីសមិទ្ធកម្ម វដ្តថវិកា ចំណាត់ថ្នាក់ថវិកា និងទម្រង់របាយការណ៍
  - ផ្តល់សិទ្ធិស្វ័យសម្រេចក្នុងការវិភាជ និងអនុវត្តថវិកាដល់រដ្ឋបាលថ្នាក់-ក្រោមជាតិនីមួយៗ
- *ដូចនេះនឹងត្រូវ÷*
  - រៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ជាផ្នែកនៃប្រព័ន្ធថវិកាជាតិ
  - កសាងប្រព័ន្ធ FMIS ដែលមានដំណើរការល្អ និងបំពេញមុខងារគ្រប់ជ្រុងជ្រោយ រហូតដល់ថ្នាក់ក្រោមជាតិ ។

# ក្របខ័ណ្ឌទស្សនទាននៃសមាហរណកម្មផែនការនីយកម្ម
# ថវិកាថ្នាក់ជាតិ និង ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ



# ៣.៦. ការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ (ត)

## ➢ ការរៀបចំ BSP និងថវិកាប្រចាំឆ្នាំ

- ❑ ផ្អែកលើ MTFF និង MTBF រួមតែមួយ ដោយមានកំណត់ពិដានថវិកាក្រសួង-ស្ថាប័ន និងថវិការាជធានី-ខេត្ត, ក្រុង-ស្រុក, ឃុំ-សង្កាត់នីមួយៗ
- ❑ ផ្អែកលើកម្មវិធី ដោយកំណត់សូចនាករលទ្ធផលក្នុងឆ្នាំនៃកម្មវិធី និងធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន
- ❑ ចែងក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ទាំងចំណូលផ្ទាល់ និងចំណូលផ្ទេរពីថវិកាជាតិ (ដូចបច្ចុប្បន្ន), ប៉ុន្តែនឹងកំណត់មុខងារពិនិត្យ និងអនុម័តថវិកាឱ្យច្បាស់លាស់ ។

## ➢ ការអនុវត្តថវិកា

- អនុញ្ញាតចំណាយសម្រាប់ថវិកាវិមជ្ឈការ តាមកម្មវិធីចំណាយប្រចាំឆមាស, លើកលែងតែករណីដោយឡែកមួយចំនួន
- ប្រគល់សិទ្ធិចាត់ចែងអនុវត្តថវិកាឱ្យដល់អង្គភាពថវិកានៅថ្នាក់ក្រោមជាតិ
- ប្រគល់សិទ្ធិអំណាចនិងការទទួលខុសត្រូវផ្ទាល់ដល់មន្ទីរស.ហ.វ ក្នុងការអនុវត្តមុខងារត្រួតពិនិត្យហិរញ្ញវត្ថុនិងកិច្ចលទ្ធកម្ម និងមុខងារត្រួតពិនិត្យការអនុវត្តចំណូលក្នុងក្របខ័ណ្ឌថវិកាមន្ទីរជំនាញ និងថវិការាជធានី-ខេត្ត
- ចំពោះថវិការដ្ឋបាលក្រុង-ស្រុកនិងឃុំ-សង្កាត់, អនុវត្តយន្តការត្រួតពិនិត្យតាមក្រោយតាមរយៈមុខងារគណនេយ្យករសាធារណៈ (រតនាគាររាជធានី-ខេត្ត) ដែលជាគោលការណ៍ បើកផ្តល់ថវិកាដោយផ្អែកលើរបាយការណ៍ចំណាយ (SOE) និងមុខងារអធិការកិច្ចហិរញ្ញវត្ថុ (អគ្គាធិការដ្ឋានក.ស.វ) ដែលជាគោលការណ៍ ត្រួតពិនិត្យជាយថាហេតុ ឬតាមការចាំបាច់ ប៉ុន្តែមានកម្រិតកំណត់។

# ៣.៦. ការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ (ត)

## ➢ របាយការណ៍

- ❑ មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវធ្វើរបាយការណ៍ទៅក្រសួង-ស្ថាប័ន, ហើយក្រសួង-ស្ថាប័នបូកសរុបរបាយការណ៍រួចបញ្ជូនមកក.ស.ហ.វ
- ❑ រដ្ឋបាលក្រុង-ស្រុក និងឃុំ-សង្កាត់ រាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តអនុកម្មវិធី និងសកម្មភាព ក្នុងទម្រង់ជាលទ្ធផលក្នុងឆ្នាំ ជូនក្រុមប្រឹក្សារបស់ខ្លួន
- ❑ រដ្ឋបាលរាជធានី ខេត្តត្រូវធ្វើរបាយការណ៍បូកសរុបនៅកម្រិតកម្មវិធី ហើយរាយការណ៍ទៅក្រុមប្រឹក្សារបស់ខ្លួន ព្រមទាំងក.ស.ហ.វ និង ក.ម.ផផងដែរ ។

# ៤.ផែនទីចង្អុលផ្លូវ

➢ ***អំពីវិសាលភាព៖***

- ផ្ដោតទៅលើការកែទម្រង់សមាសធាតុគន្លឹះទាំង ៤ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងខួបនៃថវិកាជាតិ គឺ ការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ, ការរៀបចំ និងការអនុម័តថវិកាប្រចាំឆ្នាំ, ការអនុវត្តថវិកា, ការតាមដាន និងវាយតម្លៃថវិកា
- គូសរំលេចពីហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់មួយចំនួន ដែលជាសមាសធាតុមិនអាចខ្វះបាននៃ BSR ប៉ុន្តែមិនមានចែងលម្អិតទេ ដោយសារការងារនេះបាន និងកំពុងអនុវត្តដោយឡែកនៅក្នុងក្របខ័ណ្ឌនៃ PFMRP
- មិនមានផែនទីចង្អុលផ្លូវសម្រាប់ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោម-ជាតិទេ ព្រោះត្រូវរៀបចំដោយឡែក ដោយផ្អែកលើក្របខ័ណ្ឌយុទ្ធសាស្ត្រដែលបានកំណត់នៅក្នុងចំណុច ៣.៦ នៃឯកសារ។

# ៤. ផែនទីចង្អុលផ្លូវ (ត)

➢ **បង្គោលចរសំខាន់ៗ៖**

<u>**ជំហានទី ១ (២០១៧-២០២១)**</u>

- ❑ គ្រប់ក្រសួង-ស្ថាប័នអនុវត្តថវិកាកម្មវិធី
- ❑ ការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធកម្មវិធីនឹងត្រូវធ្វើឱ្យបានរួចរាល់ក្នុងជំហាននេះ
- ❑ សមាហរណកម្មថវិកាចរន្ត និងវិនិយោគ ក្នុងការរៀបចំ BSP ឱ្យបានមុនឆ្នាំ ២០២០
- ❑ ក្រសួង ស្ថាប័ននឹងចាប់ផ្តើមភ្ជាប់ផែនការលទ្ធកម្ម ជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ២០១៩
- ❑ "កិច្ចសន្យាសមិទ្ធកម្ម" (performance agreement) ចាប់ផ្តើមដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ ២០១៩
- ❑ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនឹងត្រូវធ្វើវិសោធនកម្មក្នុងឆ្នាំ ២០២០

# ៤. ផែនទីចង្អុលផ្លូវ (ត)

- សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ តាមចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់សេដ្ឋកិច្ចបំពេញ នឹងដាក់ទៅគណៈរដ្ឋមន្ត្រី ចាប់ពីឆ្នាំ ២០២១
- ក្របខ័ណ្ឌតាមដាននិងវាយតម្លៃជាសារវ័ន្តមួយនឹងត្រូវរៀបចំចាប់ពីឆ្នាំ ២០១៩
- FMIS នឹងត្រូវដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពថវិកា ចាប់ពីឆ្នាំ ២០១៨។

## ជំហានទី ២ (២០២២-២០២៥)

- ផែនការយុទ្ធសាស្ត្រថវិកានឹងមានព័ត៌មានសមិទ្ធកម្មកាន់តែច្បាស់ចាប់ពីឆ្នាំ ២០២២
- កិច្ចសន្យាសមិទ្ធកម្មនឹងត្រូវពង្រីកដាក់បញ្ចូលបន្ថែមលទ្ធផលចុងក្រោយនៅឆ្នាំ ២០២៣

# ៤. ផែនទីចង្អុលផ្លូវ (ត)

- ❑ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ តាមចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់សេដ្ឋកិច្ចបំព្រួញ នឹងដាក់ទៅគណៈរដ្ឋមន្ត្រីឆ្នាំ ២០២១ (មានសូចនាករសមិទ្ធកម្មចាប់ពីឆ្នាំ ២០២២)
- ❑ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលមានមាតិកា និងទម្រង់ខាងលើ នឹងដាក់ទៅស្ថាប័ននីតិបញ្ញត្តិ នៅឆ្នាំ ២០២២ (មានសូចនាករសមិទ្ធកម្មចាប់ពីឆ្នាំ២០២៤)
- ❑ MTFF & MTBF តាមអភិក្រមថ្មី នឹងចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០២១
- ❑ រៀបចំនិងដាក់បញ្ចូលគោលការណ៍ណែនាំ និងនីតិវិធីការងារសវនកម្មសមិទ្ធកម្ម ទៅក្នុងក្របខណ្ឌសវនកម្មផ្ទៃក្នុង សម្រាប់អនុវត្តចាប់ពីឆ្នាំ ២០២២

# ៤. ផែនទីចង្កូលផ្លូវ (ត)

**ដំណាក់កាលទី ៣ (ចាប់ពីឆ្នាំ ២០២៥)**

- នីតិវិធីប្រតិបត្តិការថវិកានឹងត្រូវធ្វើឱ្យមានភាពសាមញ្ញ និងឌីជីថលនីយកម្ម តាមរយៈ FMIS
- ការត្រួតពិនិត្យហិរញ្ញវត្ថុនឹងត្រូវធ្វើតាមរយៈ FMIS
- កិច្ចលទ្ធកម្មនឹងត្រូវធ្វើប្រតិភូកម្មសិទ្ធិអំណាចបណ្ដើរៗដល់ក្រសួង-ស្ថាប័ន និងអាចឈានទៅអនុវត្តពេញលេញតាមឧត្តមានុវត្តអន្តរជាតិ នៅពេលមានក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់នៅឆ្នាំ ២០២៥
- របាយការណ៍ដែលផ្អែកលើស្តង់ដារគណនេយ្យសាធារណៈអន្តរជាតិ-ទម្រង់សាច់ប្រាក់កែសម្រួល (Modified Cash-IPSAS) ចាប់ផ្តើមនៅឆ្នាំ ២០២៥
- ក្របខ័ណ្ឌតាមដាន និងវាយតម្លៃសមិទ្ធកម្មពេញលេញនឹងត្រូវអនុវត្ត
- សវនកម្មសមិទ្ធកម្មនឹងក្លាយជាការងារចម្បងថ្មីមួយរបស់អាជ្ញាធរសវនកម្មជាតិ បន្ទាប់ពីប្រព័ន្ធថវិកាសមិទ្ធកម្មត្រូវអនុវត្តពេញលេញចាប់ពីឆ្នាំ ២០២៥

# ៤. ផែនទីចង្កូលផ្លូវ (ត)

➢ **ក្របខណ្ឌពេលវេលា និងអភិក្រមអនុវត្ត**

- BSRS នឹងត្រូវដាក់បញ្ចូលទៅក្នុង PFMRP និងផ្សារភ្ជាប់ទៅនឹងដំណាក់កាលទី ៣ និង ដំណាក់កាលទី ៤
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទត្រូវរៀបចំផែនការសកម្មភាពជាក់លាក់ទៅតាមពេលវេលាកំណត់ ដើម្បីអនុវត្តក្នុងក្របខណ្ឌនៃផែនការសកម្មភាពរួមនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រើប្រាស់អភិក្រម "គ្រឿងបង្គុំ" (Building Block Approach)
- គណៈកម្មាធិការដឹកនាំការងារ PFMRP នឹងដើរតួនាទីត្រួតពិនិត្យវឌ្ឍនភាពនៃ BSR
- អគ្គលេខាធិការដ្ឋានរបស់គណៈកម្មាធិការនេះនឹងតាមដានការអនុវត្ត និងសម្របសម្រួលការអនុវត្ត BSR ជាមួយនឹងការកែទម្រង់ដទៃទៀត

# ៤. ផែនទីចង្កូលផ្លូវ (ត)

## ➢ ហានិភ័យ

- ❑ ការពន្យារពេលនៃការកែទម្រង់ពាក់ព័ន្ធគន្លឹះណាមួយ ក្នុងនិងក្រៅវង្វង់ PFMRP ជាយថាហេតុ អាចនឹងធ្វើឱ្យ BSR ត្រូវពន្យាពេល
- ❑ ការបោះឆ្នោតសកលអាចនឹងធ្វើឲ្យការកែទម្រង់រអាក់រអួលនៅក្នុងឆ្នាំ ២០១៨ និងក្រោយឆ្នាំ ២០១៨
- ❑ ការខ្វះឆន្ទៈ ឬការយល់ដឹងពីគុណតម្លៃនៃការកែទម្រង់ ជាពិសេស ការឱប-ក្រសោបការងារអនុវត្តថវិកា
- ❑ ការតាមដាន និងរបាយការណ៍ទៀងទាត់អំពីវឌ្ឍនភាពនៃការអនុវត្ត BSRS មានសារៈសំខាន់ណាស់ ក្នុងការរកឃើញហានិភ័យដែលអាចនឹងលេចឡើង ។

# ៥. សេចក្តីសន្និដ្ឋាន

- ការសម្រេចយកចក្ខុវិស័យ តាមម៉ូដែល ***«ចក្ខុវិស័យមានសមិទ្ធកម្ម»*** ជាទិសដៅនៃ BSR រយៈពេលវែង ប្រកបដោយភាពប្រាកដនិយម និង សមស្របសម្រាប់កម្ពុជា, ទាំងពេលវេលា និង សមត្ថភាពស្ថាប័ន។

- ការដាក់ចេញគោលដៅថ្មី <u>នៅតែមានមហិច្ឆតាខ្ពស់</u> និងបានកំណត់ឃើញនូវហានិភ័យសំខាន់ៗមួយចំនួន ដែលអាចជួបប្រទះនៅក្នុងពេលអនុវត្ត, ប៉ុន្តែចាំបាច់ត្រូវតែពុះពារសម្រេចឱ្យបានជាសារវន្ត ដើម្បីឆ្លើយតបទៅនឹងបរិការណ៍កម្ពុជាដែលកំពុងឈានដល់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ក៏ដូចជានិន្នាការថ្មីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអន្តរជាតិ ។

# ៦. សេចក្តីសន្និដ្ឋាន (ត)

- ចំណុចគន្លឹះក្នុងការធានាឱ្យបានជោគជ័យនៃ PFMRP  និង BSR ÷
  - ❑ ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ជាពិសេសការគាំទ្រយ៉ាងមុតមាំ និងឥតងាករេពី **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
  - ❑ ភាពជាម្ចាស់នៃតួអង្គពាក់ព័ន្ធក្នុងការអនុវត្តការងារកែទម្រង់
  - ❑ ការចូលរួមពីដៃគូអភិវឌ្ឍន៍ដើម្បីផ្តល់នូវការគាំទ្រខាងចំណេះដឹង និងការបន្តដើរតួនាទីចូលរួមតាមដានរបៀបវារៈកែទម្រង់ និងសហការបង្កើតជាបរិស្ថានល្អសម្រាប់ការអនុវត្តកែទម្រង់ ។

# សូមអរគុណ